**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្តេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចក្រឡាហោម** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យមានការរីកចម្រើន ថ្មីៗបន្តទៀត។

នាឱកាសនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសមានចិត្តគោរពស្មោះស្ម័គ្រ និងកោតសរសើរយ៉ាងក្រៃលែង នូវការដឹកនាំរបស់ **សម្តេចក្រឡាហោម** ដែលជានិច្ចកាល **សម្តេច** តែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ និង ប្រាជ្ញាស្មារតី ជាមួយនឹងបទពិសោធន៍ដ៏ប៉ិនប្រសប់ប្រកបដោយគំនិតផ្តួចផ្តើមអស់ពេញភាពដ៏មោះមុតសម្រេចបាននូវស្នាដៃ និងសមិទ្ធផល ជាច្រើនគួរឱ្យស្ញប់ស្ញែងជាបន្តបន្ទាប់។ ជាពិសេសទប់ស្កាត់បាននូវសកម្មភាពភេរវកម្មគ្រប់ប្រភេទ ព្រមទាំងរក្សា បាននូវ សន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមបានយ៉ាងរឹងមាំ ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយ ភាពកក់ក្តៅ និងមានទំនុកចិត្តជាខ្លាំងលើរាជរដ្ឋាភិបាលកម្ពុជា។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិ ទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូន **សម្តេចក្រឡាហោម** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់សូមបាន សមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ** សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃអង្គារ ៦រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៤: generalsec@mod.gov.kh